# ទទ្ទរជាតក



*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុក្រោធមួយរូប បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **ឥមានិ មំ** *ដូច្នេះជាដើម ។*

*រឿងរ៉ាវជាតកនេះបានពោលរួចមកហើយក្នុង (ជាតក) ក្រោយ ។ ក្នុងពេលនោះ កាលភិក្ខុទាំងឡាយពោលដល់ភាពក្រោធរបស់ភិក្ខុនោះ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នារឿងអ្វី ? កាលពួកភិក្ខុទូលថា ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ឲ្យហៅភិក្ខុនោះមក ហើយត្រាស់ថា ម្នាលភិក្ខុបានឮថា អ្នកក្រោធឬ ? កាលភិក្ខុនោះទូលថា ពិតមែនហើយព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏ជាអ្នកក្រោធដែរ និងព្រោះភាពជាអ្នកក្រោធនោះឯង (ធ្វើឲ្យ) បោរាណបណ្ឌិតជាអ្នកបរិសុទ្ធ ដែលឋិតនៅក្នុងភាពជានាគរាជ ក៏ត្រូវទៅរស់នៅក្នុងផែនដីកខ្វក់ ដែលពេញដោយគូថ អស់ ៣ ឆ្នាំ ដូច្នេះហើយព្រះអង្គនាំយកអតីតនិទានមកថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី មានពិភពនាគឈ្មោះ **ទទ្ទរនាគ** នៅនឹងជើងភ្នំទទ្ទរបព៌ត ក្នុងហិមវន្តប្រទេស (កាលនោះ) ព្រះពោធិសត្វជាបុត្ររបស់ទទ្ទរនាគរាជដែលសោយរាជសម្បត្តិក្នុងទីនោះ លោកមានឈ្មោះថា **មហាទទ្ទរៈ** ហើយលោកមានប្អូនប្រុសមួយឈ្មោះ **ចូឡទទ្ទរៈ** ។ ចូឡទទ្ទរនាគនោះជានាគក្រោធ អាក្រក់ តែងត្រាច់ដេរ ប្រទេច ផ្តាសា វាយប្រហារពួកនាគកំលោះ ។ ស្តេចនាគជាបិតាដឹងភាពអាក្រក់របស់ចូឡទទ្ទរនាគនោះ ក៏បញ្ជាឲ្យបណ្តេញចេញពីនាគពិភព ។ មហាទទ្ទរនាគសូមបិតាឲ្យអត់ទោសដល់ប្អូន និងបានហាមឃាត់ប្អូន ។ សូម្បីលើកទីពីរ ព្រះរាជាក្រោធបំពោះចូឡទទ្ទរនាគនោះទៀត ព្រះពោធិសត្វក៏សូមឲ្យអត់ទោសជាលើកទីពីរ ។ តែក្នុងវារៈទីបី ស្តេចនាគត្រាស់ថា អ្នកហាមមិនឲ្យបិតានិរទេសនាគ ដែលប្រព្រឹត្តអនាចារ អ្នកចូរទៅចុះ សូម្បីអ្នកទាំងពីរត្រូវចេញពីពិភពនាគនេះ ចូរទៅរស់នៅក្នុងផែនដីប្រកបដោយគូថ អស់ ៣ ឆ្នាំចុះ ដូច្នេះហើយ ទ្រង់បញ្ជាឲ្យនាគបុរសចាប់អូសចេញពីពិភពនាគ ។ នាគទាំងពីរនោះក៏បានទៅរស់នៅក្នុងទីនោះ ។ លំដាប់នោះ ពួកក្មេងអ្នកស្រុកឃើញនាគទាំងនោះ ដែលកំពុងស្វែងរកចំណីនៅទីបំផុតទឹក ត្រង់កន្លែងដែលប្រកបគូថ ហើយនាំគ្នាវាយប្រហារ យកដុំដីនិងដំបងគប់គ្រវែងទៅ ហើយក៏ពោលជេរប្រទេចថា នាគនេះជាអ្វីអេះ មានក្បាលធំ មានកន្ទុយដូចម្ជុល ដូចពស់ទឹក មានកង្កែបជាអាហារ ។*

*ចូឡទទ្ទរនាគ ព្រោះភាពជានាគកាចអាក្រក់ ទើបមិនអាចអត់ធន់នឹងការមើលងាយរបស់ក្មេងទាំងនោះ ក៏ពោលនឹងបងថា បពិត្របងប្រុស ក្មេងទាំងនេះមើលងាយពួកយើង ពួកគេមិនដឹងភាពជាអ្នកមានពិសរបស់យើង ខ្ញុំមិនអាចអត់ធន់នឹងការមើលងាយ របស់ពួកក្មេងនោះទេ ខ្ញុំនឹងឲ្យក្មេងទាំងនោះវិនាសដោយខ្យល់ច្រមុះ ដូច្នេះកាលនឹងចរចាជាមួយបងប្រុស ទើបពោលគាថាទី ១ ថា*

**ឥមានិ មំ ទទ្ទរ តាបយន្តិ, វាចាទុរុត្តានិ មនុស្សលោកេ;**
**មណ្ឌូកភក្ខា ឧទកន្តសេវី, អាសីវិសំ មំ អវិសា សបន្តិ។**

*បពិត្រមហាទទ្ទរៈ ពាក្យអាក្រក់ទាំងឡាយនេះ ក្នុងមនុស្សលោក ធ្វើខ្ញុំឲ្យក្តៅក្រហាយ ឯពួកក្មេងទាំងឡាយនេះ មិនមានពិសសោះ ប៉ុន្តែហ៊ានជេរខ្ញុំ ដែលមានពិស ថាជាអ្នកស៊ីកង្កែបផង នៅក្នុងទឹកផង ។*

*មហាទទ្ទរនាគស្តាប់ពាក្យរបស់ចូឡទទ្ទរនាគនោះហើយ ក៏ពោលគាថាដ៏សេសថា*

**សកា រដ្ឋា បព្វាជិតោ, អញ្ញំ ជនបទំ គតោ;**
**មហន្តំ កោដ្ឋំ កយិរាថ, ទុរុត្តានំ និធេតវេ។**

*បុគ្គលដែលគេបំបរបង់ចេញចាកដែនរបស់ខ្លួនហើយ ទៅកាន់ជនបទឯទៀត ត្រូវធ្វើជង្រុកឲ្យធំ ដើម្បីដាក់នូវពាក្យអាក្រក់ទាំងឡាយចុះ ។*

**យត្ថ បោសំ ន ជានន្តិ, ជាតិយា វិនយេន វា;**
**ន តត្ថ មានំ កយិរាថ, វសមញ្ញាតកេ ជនេ។**

*ពួកជនមិនដឹងនូវបុរសដោយជាតិ ឬដោយវិន័យ គឺគុណសម្បត្តិ ក្នុងទីណា បុគ្គលកាលទៅក្នុងសំណាក់ នៃពួកជនដែលខ្លួនមិនស្គាល់ មិនត្រូវធ្វើសេចក្តីប្រកាន់ ក្នុងទីនោះឡើយ ។*

**វិទេសវាសំ វសតោ, ជាតវេទសមេនបិ;**
**ខមិតព្វំ សបញ្ញេន, អបិ ទាសស្ស តជ្ជិតំ។**

*បុគ្គលប្រកបដោយប្រាជ្ញា ( សូម្បីមានអានុភាព) ស្មើដោយភ្លើង កាលនៅក្នុងប្រទេសដទៃ ត្រូវតែអត់សង្កត់ពាក្យ ទោះបីមនុស្សជាខ្ញុំគេគំរាមក៏ដោយ ។*

នាគទាំងពីររស់នៅក្នុងទីនោះ អស់ ៣ ឆ្នាំ ។ ពេលនោះ ស្តេចនាគជាបិតាឲ្យគេហៅនាគទាំងនោះមកវិញ ។ ចាប់ពីពេលនោះមក នាគទាំងនោះក៏អស់មានះ ។

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ និងប្រជុំជាតក ពេលចប់សច្ចធម៌ ភិក្ខុក្រោធបានតាំងនៅក្នុងអនាគាមិផល ។

**តទា ចូឡទទ្ទរោ កោកជោ ភិក្ខុ អហោសិ** ចូឡទទ្ទរនាគក្នុងកាលនោះ បានមកជា ភិក្ខុក្រោធនេះ

**មហាទទ្ទរោ បន អហមេវ អហោសឹ** ចំណែកមហាទទ្ទរនាគគឺតថាគតនេះឯង ។

ទទ្ទរជាតក ចប់ ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ជាតក ចតុក្កនិបាត កាលិង្គវគ្គ ទទ្ទរជាតក បិដកលេខ ៥៨ ទំព័រ ១៨៩)

ថ្ងៃ ពុធ ៣ រោច ខែស្រាពណ៍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០
ថ្ងៃទី ២៩ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨
ដោយស.ដ.វ.ថ.